UK Government

# សេចក្តីប្រកាសព័ត៌មាន៖

## ចក្រភពអង់គ្លេសបរិច្ចាគវ៉ាក់សាំងកូវីដ១៩ AstraZeneca ចំនួន ៤១៥,០០០ដូស ដល់ប្រទេសកម្ពុជាតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី

- វ៉ាក់សាំងចំនួនប្រាំបួនលានត្រូវបានបរិច្ចាគទៅកាន់ប្រទេសជាច្រើនតាមរយៈកច្ចិព្រមព្រៀងទ្វេភាគី និងយន្តការ COVAX ដើម្បីដោះស្រាយបញ្ហា Covid-19
- វ៉ាក់សាំងត្រូវបានគេរំពឹងថានឹងចាកចេញពីចក្រភពអង់គ្លេសនៅសប្តាហ៍នេះ ដោយប្រទេសកម្ពុជាក៏ស្ថិតក្នុងចំណោមបណ្តាប្រទេសដ៏ទៃទៀតដែលនឹងទទួលបានវ៉ាក់សាំងទាំងនេះដែរ
- ចក្រភពអង់គ្លេសបានប្តេជ្ញាថានឹងបរិច្ចាគវ៉ាក់សាំងចំនួន ១០០ លានដូសដល់ប្រទេសនានានៅត្រឹមខែមិថុនាឆ្នាំ ២០២២ ដែល ៨០ លានដូសនៃចំនួននេះនឹងត្រូវបានបរិច្ចាគតាមរយៈយន្តការ COVAX

ក្នុងសប្តាហ៍នេះចក្រភពអង់គ្លេសនឹងចាប់ផ្តើមបញ្ជូនវ៉ាក់សាំង Covid-19 ចំនួន ៩ លានដូសទៅកាន់ប្រទេសជាច្រើនទូទាំងពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ ដើម្បីដោះស្រាយបញ្ហាCovid-19។ រដ្ឋមន្ត្រីក្រសួងការបរទេស Dominic Raab បានប្រកាសនៅថ្ងៃនេះ (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១)

វ៉ាក់សាំងចំនួន ៥ លានដូសត្រូវបានផ្តល់ឱ្យយន្តការ COVAX ដែលជាគម្រោងដើម្បីធានាបាននូវការទទួលវ៉ាក់សាំង Covid-19 ដែលមានលក្ខណៈសកលនិងស្មើភាពគ្នា។ យន្តការ COVAX នឹងចែកចាយជាបន្ទាន់ដល់បណ្តាប្រទេសដែលមានប្រាក់ចំណូលទាបតាមរយៈប្រព័ន្ធបែងចែកប្រកបដោយសមធម៌ដែលផ្តល់អាទិភាពក្នុងការផ្តល់វ៉ាក់សាំងដល់ប្រជាជនដែលត្រូវការបំផុត។ វ៉ាក់សាំងចំនួន ៤ លានដូសទៀតនឹងត្រូវចែកចាយដោយផ្ទាល់ដល់ប្រទេសដែលត្រូវការ។

ប្រទេសកម្ពុជានឹងទទួលបានវ៉ាក់សាំងចំនួន ៤១៥.០០០ ដូស ក្នុងចំណោមបណ្តាប្រទេសដទៃទៀត។

ចក្រភពអង់គ្លេសកំពុងបរិច្ចាគវ៉ាក់សាំងរបស់សាកលវិទ្យាល័យ Oxford-AstraZeneca ដែលផលិតដោយ Oxford Biomedica នៅ Oxford និងវេចខ្ចប់នៅ Wrexham, North Wales ។

នេះជាវ៉ាក់សាំង ១០០ លានដូសដំបូងបង្អស់ដែលលោកនាយករដ្ឋមន្ត្រីបានប្តេជ្ញាថាចក្រភពអង់គ្លេសនឹងចែកចាយក្នុងរយៈពេលមួយឆ្នាំទៀតនៅក្នុងកិច្ចប្រជុំ G7 កាលពីខែមុន នៅ Cornwall ដោយ ៣០ លានដូសនឹងត្រូវបញ្ជូននៅជំណាច់ឆ្នាំនេះ។ យ៉ាងហោចណាស់ ៨០ លានដូសក្នុងចំណោម ១០០ លានដូសនឹងត្រូវផ្តល់ឱ្យយន្តការ COVAX ហើយចំនួនដែលនៅសេសសល់នឹងផ្តល់ទៅប្រទេសផ្សេងៗទៀតដោយផ្ទាល់។ ការបរិច្ចាគនេះធ្វើតាមការប្តេជ្ញាដែលមេដឹកនាំ G7 បានសន្យាដើម្បីចាក់វ៉ាក់សាំងឱ្យមនុស្សទូទាំងពិភពលោក និងបញ្ចប់ការរាតត្បាតនៅឆ្នាំ ២០២២ ។

ការបញ្ជូនវ៉ាក់សាំងនៅសប្តាហ៍នេះនឹងជួយបំពេញតម្រូវការវ៉ាក់សាំងក្នុងបណ្តាប្រទេសនានាជុំវិញពិភពលោក រួមទាំងនៅទ្វីបអាហ្វ្រិក អាស៊ីអាគ្នេយ៍ និងការ៉ាបៀន។ តំបន់ទាំងនេះកំពុងជួបប្រទះបញ្ហារីករាលដាលខ្លាំងនៃការចម្លង Covid-19 ការព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់ដោយ Covid-19។

**រដ្ឋមន្ត្រីក្រសួងការបរទេស Dominic Raab មានប្រសាសន៍ថា៖**

> *"ចក្រភពអង់គ្លេសនឹងបញ្ជូនវ៉ាក់សាំង AstraZeneca ចំនួន ៤១៥,០០០ ដូសទៅកាន់ប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃការផ្តល់វ៉ាក់សាំងចំនួន ១០០ លានដូសដំបូងដែលយើងបានប្តេជ្ញា ដើម្បីជួយឱ្យតំបន់ដែលក្រីក្របំផុតនៃពិភពលោកបានទទួលការចាក់វ៉ាក់សាំងក្នុងករណីបន្ទាន់។ យើងកំពុងធ្វើការដើម្បីជួយអ្នកដែលងាយរងគ្រោះបំផុត ហើយក៏ព្រោះតែយើងដឹងថា យើងនឹងមិនមានសុវត្ថិភាពទេ រហូតទាល់តែមនុស្សគ្រប់គ្នាមានសុវត្ថិភាព។"*

ចក្រភពអង់គ្លេសបានឈានមុខគេក្នុងការឆ្លើយតបជាសកលដើម្បីដោះស្រាយបញ្ហា Covid-19 រួមទាំងតាមរយៈការវិនិយោគ ៩០ លានផោនដើម្បីគាំទ្រដល់ការបង្កើតវ៉ាក់សាំង Oxford-AstraZeneca ។ វ៉ាក់សាំង Oxford-AstraZeneca ចំនួនជាង៥០០លានដូស ត្រូវបានផ្តល់ឱ្យនៅទូទាំងពិភពលោកក្នុងតម្លៃដែលមិនស្វែងរកប្រាក់ចំណេញ និងពីរភាគបីនឹងបញ្ជូនទៅកាន់ប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម។

ចក្រភពអង់គ្លេសក៏បានចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតយន្តការ COVAX នៅឆ្នាំ ២០២០ ដោយផ្តល់ថវិកាសរុបចំនួន ៥៤៨ លានផោន ដើម្បីផ្តល់វ៉ាក់សាំងដល់ប្រទេសដែលមានប្រាក់ចំណូលទាប។ គម្រោងនេះបានផ្តល់នូវវ៉ាក់សាំងជាង ១៥២ លានដូសដល់ជាង ១៣៧ ប្រទេសក្នុងនោះមាន ៨៣ ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ៦៥ ភាគរយនៃវ៉ាក់សាំងដំបូងគឺ Oxford-AstraZeneca ។ យន្តកា COVAX មានគោលបំណងផ្តល់វ៉ាក់សាំងចំនួន ១,៨ ពាន់លានដូសដល់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅជុំវិញពិភពលោកនៅដើមឆ្នាំ ២០២២ ។

**លោកជំទាវឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំនៅកម្ពុជា Tina Redshaw មានប្រសាសន៍ថា៖**

> *"វ៉ាក់សាំង AstraZeneca ចំនួន ៤១៥,000 ដូសនេះនឹងជួយដល់សហគមន៍ក្នុងមូលដ្ឋានដើម្បីចាប់ផ្តើមអាជីវកម្ម ការពារសេវាសុខភាព និងស្តារជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាឡើងវិញ។ ខ្ញុំពិតជារីករាយដែលចក្រភពអង់គ្លេសប្តេជ្ញាចិត្តក្នុងការបរិច្ចាគវ៉ាក់សាំងនៅទូទាំងពិភពលោកទាំងតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និងយន្តការ COVAX ហើយក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។"*